មុនការជូនដំណឹងជាលាយលក្ខណ៍អក្សរ – ផ្នែក ខ (Part B)

កាលបរិច្ឆេទ ៖

ឈ្មោះសិស្ស ៖

លេខ MARSS ៖

សាលា ៖

ថ្នាក់ ៖

ថ្ងៃខែឆ្នាំកំណើត ៖

ជូនចំពោះ ៖

អ្នកបានទទួលសេចក្តីជូនដំណឹងនេះ ដោយសារ 1) មណ្ឌលសិក្សាស្រុកកំពុងតែស្នើសុំ និង/ឬកំពុងតែបដិសេធចំពោះការផ្លាស់ប្តូរមួយចំនួនដូចខាងក្រោម លើអត្តសញ្ញាណកម្ម ការវាយតម្លៃ ការចាត់ឲ្យចូលរៀន ឬការផ្តល់ឲ្យនូវការអប់រំសាធារណៈដែលសមរម្យ (FAPE) មួយសម្រាប់កូនអ្នក ឬ 2) អ្នកបានដកហូតមកវិញនូវការយល់ព្រមឲ្យកូនអ្នកទទួលសេវា ជាលាយលក្ខណ៍អក្សរ ។

សំណើសុំ

1. ការពណ៌នាអំពីសកម្មភាព ដែលស្នើឡើងដោយមណ្ឌលសិក្សាស្រុក ៖

2. ការពន្យល់ពីមូលហេតុដែលមណ្ឌលសិក្សាស្រុក ស្នើសុំអនុវត្តសកម្មភាព ៖

3. ការពណ៌នាអំពីទម្រង់ការនៃការវាយតម្លៃ ការធ្វើតេស្ត កំណត់ត្រា ឬរបាយការណ៍នីមួយៗ ដែលមណ្ឌលសិក្សាស្រុកបានប្រើសម្រាប់ជាគោល ក្នុងការស្នើសុំអនុវត្តសកម្មភាព ៖

4. ការពណ៌នាអំពីជម្រើសផ្សេងទៀត ដែលក្រុមកម្មវិធីអប់រំឯកវាជ្យបានពិចារណា និងមូលហេតុអំពីការបដិសេធចោលនូវជម្រើសទាំងអស់នោះ ៖

5. ការពណ៌នាអំពីកត្តាផ្សេងៗទៀត ដែលប៉ះពាល់ដល់សំណើសុំ ៖

ការបដិសេធ

1. ការរៀបរាប់អំពីសកម្មភាពដែលមណ្ឌលសិក្សាស្រុកបដិសេធចោល ៖

2. ការពន្យល់អំពីមូលហេតុដែលមណ្ឌលសិក្សាបដិសេធមិនអនុវត្តសកម្មភាព ៖

3. ការរៀបរាប់អំពីទម្រង់ការនៃការវាយតម្លៃ ការធ្វើតេស្ត កំណត់ត្រា ឬរបាយការណ៍នីមួយៗ ដែលមណ្ឌលសិក្សាស្រុក បានយកមកប្រើ
   ដើម្បីជាគោលសម្រាប់ការបដិសេធលើការសកម្មភាពដែលបានស្នើសុំ ៖

4. ការពណ៌នាអំពីជម្រើសដទៃទៀត ដែលក្រុម IEP បានពិចារណា
   និងមូលហេតុនៃការបដិសេធចំពោះជម្រើសទាំងនោះ ៖

5. ការពណ៌នាអំពីកត្តាផ្សេងៗទៀតដែលប៉ះពាល់ដល់ការបដិសេធ ៖

ពេលមណ្ឌលសិក្សាស្រុកស្នើ ឬបដិសេធចំពោះការផ្តួចផ្តើមគំនិត ឬផ្លាស់ប្តូរអត្តសញ្ញាណកម្ម ការវាយតម្លៃ ឬការដាក់ឲ្យកូនអ្នកចូលរៀន ឬការផ្តល់ឲ្យនូវ FAPE ដល់កូនអ្នក
ឬពេលអ្នកដកហូតសេចក្តីយល់ព្រមទទួលសេវាកម្ម មកវិញជាលាយលក្ខណ៍អក្សរ
មណ្ឌលសិក្សាស្រុកត្រូវតែជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ នៅមុនពេលការផ្លាស់ប្តូរត្រូវចូលជាធរមាន ។ សេចក្តីជូនដំណឹងនេះ ត្រូវតែផ្តល់ជូនអ្នកក្នុងរយៈពេលមួយដែលសមរម្យ ហើយមិនត្រូវតិចជាង 14 ថ្ងៃ នៃប្រតិទិន នៅមុនពេលកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ឬការវាយតម្លៃត្រូវចូលជាធរមាន ។

ប្រសិនបើការជូនដំណឹងនេះ គ្រាន់តែរួមបញ្ចូលនូវសេចក្តីបដិសេធចំពោះការស្នើសុំ
សេចក្តីជូនដំណឹងនេះនឹងត្រូវផ្តល់ជូនអ្នកក្នុងកំឡុងពេល 14 ថ្ងៃនៃប្រតិទិន
ដោយចាប់គិតពីកាលបរិច្ឆេទដែលការស្នើសុំរបស់អ្នកត្រូវបានធ្វើឡើង ។

មណ្ឌលសិក្សាស្រុក នឹងមិនចាត់ការជាមួយនឹងការដាក់ឲ្យក្មេងចូលរៀនដំបូង និងការផ្តល់ឲ្យនូវសេវាកម្ម
ដោយគ្មានការយល់ព្រមពីអ្នកជាលាយលក្ខណ៍អក្សរឡើយ ។

លើកលែងតែចំពោះការដាក់ឲ្យក្មេងចូលរៀនដំបូង និងការផ្តល់ឲ្យនូវសេវាកម្ម មណ្ឌលសិក្សាស្រុក
នឹងចាត់ការចំពោះការស្នើដាក់ឲ្យក្មេងចូលរៀន និងការផ្តល់ឲ្យនូវសេវាកម្ម ប្រសិនបើអ្នកជំទាស់
ជាលាយលក្ខណ៍អក្សរ នៅក្នុងបែបបទឆ្លើយតបដែលមានភ្ជាប់មកជាមួយ ឬបើមិនដូច្នេះទេ ធ្វើឡើង
ជាលាយលក្ខណ៍អក្សរ ក្នុងរវាង 14 ថ្ងៃនៃប្រតិទិន ក្រោយពេលអ្នកបានទទួលសេចក្តីជូនដំណឹងនឹះ ។

បើអ្នកបដិសេធមិនផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ចំពោះការវាយតម្លៃដំបូង ឬការដាក់
ឲ្យក្មេងចូលរៀនដំបូង ឬការជំទាស់ជាលាយលក្ខណ៍អក្សរចំពោះសំណើសុំណាមួយ ឬប្រសិនបើ
មណ្ឌលសិក្សាស្រុកបដិសេធធ្វើការផ្តួចផ្តើមគំនិត ឬការផ្លាស់ប្តូរអត្តសញ្ញាណកម្ម ការវាយតម្លៃ
ឬការដាក់ឲ្យក្មេងចូលរៀន ឬការផ្តល់ឲ្យនូវការអប់រំសាធារណៈដែលសមស្របដោយមិនបាច់បង់ប្រាក់
ចំពោះកូនអ្នក ក្នុងនាមជាឪពុកម្តាយក្មេង អ្នកអាចស្នើសុំធ្វើសន្និសិទផ្សះផ្សារ ដើម្បីដោះស្រាយចំពោះបញ្ហា
មិនចុះសម្រុងនឹងគ្នាណាមួយ ស្តីអំពីសំណើសុំ ឬការបដិសេធ ។

មណ្ឌលសិក្សាស្រុក ត្រូវតែផ្តល់ឲ្យអ្នកនូវសំណៅថតចម្លងនៃ IEP ដែលបានស្នើឡើង
នៅពេលណាដែលមណ្ឌលសិក្សាស្រុកបានលើកជាសំណើ ដើម្បីផ្តួចផ្តើមគំនិត ឬប្តូរខ្លឹមសារ IEP ។

អ្នកត្រូវបានទទួលការការពារពីទម្រង់ការសុវត្ថិភាព ហើយអាចបានទទួលការរៀបរាប់អំពីទម្រង់ការ សុវត្ថិភាព
ដោយការស្នើសុំទម្រង់ការទាំងនេះពី ៖

ឈ្មោះ ៖

តួនាទី ៖

លេខទូរស័ព្ទ ៖

ភ្នាក់ងារខាងក្រោម អាចជួយអ្នកឲ្យបានយល់អំពីសិទ្ធិរបស់ខ្លួន និងសិទ្ធិរបស់កូនអ្នក ក្រោមច្បាប់រដ្ឋ និងច្បាប់ការអប់រំពិសេសរបស់សហព័ន្ធ ៖

Advocacy for Persons with Developmental Disabilities (ARC)
(ការតស៊ូមតិសម្រាប់មនុស្សពិការ)
651-523-0823
800-582-5256
www.thearcofminnesota.org

Minnesota Department of Education
(ក្រសួងអប់រំនៃរដ្ឋមីណេសូតា)
651-582-8689
ទូរស័ព្ទសម្រាប់មនុស្សខ្វាក់គថ្លង់ ៖ 651-582-8201
http://education.state.mn.us

Minnesota Disability Law Center
(មជ្ឈមណ្ឌលច្បាប់សម្រាប់ជនពិការរដ្ឋមីណេសូតា)
612-334-5970
800-292-4150
ទូរស័ព្ទសម្រាប់មនុស្សខ្វាក់គថ្លង់ ៖ 612-332-4668
www.mndlc.org

Parent Advocacy Coalition for Education Rights (PACER)
(សម្ព័ន្ធតស៊ូមតិរបស់មាតាបិតា ដើម្បីសិទ្ធិទទួលការអប់រំ)
952-838-9000
800-53-PACER
ទូរស័ព្ទសម្រាប់មនុស្សខ្វាក់គថ្លង់ ៖ 952-838-0190
www.pacer.org

សេចក្ដីជូនដំណឹងអំពីការវាយតម្លៃ

ប្រសិនបើសេចក្ដីជូនដំណឹងនេះ ពាក់ព័ន្ធជាមួយនឹងការវាយតម្លៃ អ្នកគួរតែប្រុងប្រយ័ត្នចំពោះចំណុចខាងក្រោម ៖

ការវាយតម្លៃ មានន័យថា ការប្រើទម្រង់ការដែលសមស្រប ដើម្បីរកឲ្យឃើញថាតើ កុមារមានពិការភាពឬទេ ព្រមទាំងរកឲ្យឃើញនូវវិសាលភាពនៃសេវាកម្មអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាដែលកុមារត្រូវការ ។

ការយល់ព្រមរបស់អ្នកដែលធ្វើឡើងតាមការបានដឹងព័ត៌មានជាមុន គឺជាអ្វីដែលជាភាពតម្រូវ នៅមុនពេលដែលមណ្ឌលសិក្សាស្រុកអាចចាត់ការជាមួយនឹងការវាយតម្លៃ លើកលែងតែក្នុងករណីដែល

មណ្ឌលសិក្សាស្រុក យកទិន្នន័យដែលមានស្រាប់ ការសង្កេតក្នុងថ្នាក់រៀន ឬបានចាត់វិធានការ
យកមកប្រើជាសំអាង ដើម្បីបានទទួលសេចក្តីយល់ព្រមរបស់អ្នក សម្រាប់ការវាយតម្លៃឡើងវិញ
ហើយអ្នកខកខានមិនបានឆ្លើយតប អំពីបញ្ហានេះ ។ ការផ្តល់សេចក្តីយល់ព្រមរបស់អ្នក គឺជាអ្វីដែលធ្វើឡើង
ដោយការស្ម័គ្រចិត្ត ហើយអាចដកហូតមកវិញបានគ្រប់ពេល ។ រាល់ការដកហូតសេចក្តីយល់ ព្រមមកវិញ
នឹងមិនបណ្តាលឲ្យកើតមានប្រតិសកម្មឡើយ ។

ការវាយតម្លៃរបស់កូនអ្នក ត្រូវតែមានភាពទូលំទូលាយគ្រប់គ្រាន់
សម្រាប់កំណត់រកឲ្យឃើញនូវសេចក្តីត្រូវការចំពោះការអប់រំពិសេស និងសេវាកម្មនានាដែលពាក់ព័ន្ធ
មិនថាតម្រូវការទាំងនេះត្រូវភ្ជាប់ជា មួយនឹងប្រភេទនៃពិការភាពដែលមានការសង្ស័យ
ឬភ្ជាប់ទៅនឹងក្រុមនៃពិការភាពដែលកូនរបស់អ្នក ស្ថិតនៅក្នុងនោះ ។ ការវាយតម្លៃ
រួមទាំងសេវាកម្មវេជ្ជសាស្ត្រនានាដែលជាតម្រូវការ ដើម្បីកំណត់រក ឲ្យឃើញនូវពិការភាពពាក់ព័ន្ធនឹងវេជ្ជសាស្ត្ર
នឹងធ្វើឡើងដោយអ្នកមិនចាំបាច់បង់ប្រាក់ឡើយ ។

សូមពិនិត្យមើលឡើងវិញអំពីបញ្ជីប្រភេទការធ្វើតេស្តដែលបានស្នើឡើង ដូចខាងក្រោម
ហើយផ្តល់សេចក្តីយល់ព្រម ដោយការចុះហត្ថលេខាលើបែបបទដែលបានដាក់ភ្ជាប់មកជាមួយ រួចហើយផ្ញើវា
ត្រឡប់មកវិញ ។ ការផ្តល់សេចក្តីយល់ព្រម សម្រាប់ការវាយតម្លៃដំបូង មិនមែនជាការផ្តល់សេចក្តីយល់ព្រម
ដើម្បីទទួលយកនូវការអប់រំពិសេស និងសេវាកម្មនានាដែលពាក់ព័ន្ធឡើយ ។

☐ បើអ្នកគ្រីសលើប្រអប់មួយនេះ មិនចាំបាច់ធ្វើតេស្តបន្ថែម ដើម្បីកំណត់រកឲ្យឃើញថាតើកូនរបស់អ្នក
នៅមិនទាន់បាត់បង់នូវពិការភាព ហើយកូនរបស់អ្នកនឹងនៅតែត្រូវការសេវាកម្មការអប់រំពិសេស
ដោយសំអាងលើការវិវេចនាលើទិន្នន័យដែលមានស្រាប់ ដូចមានចែងក្នុងសេចក្តីជូនដំណឹងនេះឡើយ ។
មូលហេតុសម្រាប់ការកំណត់រកឲ្យឃើញនេះ ត្រូវបានដាក់បញ្ចូលក្នុងសេចក្តីជូនដំណឹងនេះ ។
អ្នកមានសិទ្ធិស្នើសុំការធ្វើតេស្តបន្ថែម ដើម្បីកំណត់រកឲ្យឃើញថាតើកូនរបស់អ្នក កំពុងស្ថិតនៅជាក្មេងពិការ
ឬមួយថារូបគេនឹងនៅត្រូវការសេវាកម្មអប់រំពិសេសឬទេ ។